# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ១៣ មេសា ២០២០

## *ការពន្យារពេលប្រមូលពន្ធរហូតដល់ថ្ងៃ ១ មិថុនា*

## *កំណត់ត្រាពីករណីថ្មីៗ នឹងមានផ្សាយលើ* Revere.org

ថ្ងៃទី ១៣ មេសា ២០២០២ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 ចំនួន ៥៥៥ នាក់ នៅក្នុងក្រុង Revere។

ថ្ងៃនេះលោកអភិបាល Arrigo បានប្រកាសពីកាលបរិច្ឆេទនៃការពន្យារពេលប្រមូលពន្ធអចលនទ្រព្យពីថ្ងៃទី ១ ឧសភា ២០២០ ទៅថ្ងៃទី ១ មិថុនា ២០២០ វិញ។ កាលបរិច្ឆេទថ្មីនេះ នឹងត្រូវបានប្រើប្រាស់ជាផ្លូវការសម្រាប់ទាំងអ្នកស្នើការសុំលើកលែងពន្ធ និងចង់ពន្យារពេងបង់ពន្ធ ដែលមានកាលផុតកំណត់ត្រឹមថ្ងៃ ១ មេសា។ ដរាបណាអ្នកបង់ពន្ធមុន ឬនៅថ្ងៃ ៣០ មិថុនា ២០២០ សាលាក្រុងនឹងមិនយកថ្លៃការប្រាក់ និងធ្វើការផាកពិន័យឡើយ ប្រសិនបើវិក័យប័ត្រនោះ មានកាលផុតកំណត់ត្រឹមថ្ងៃ ១០ មិនា ២០២០ ។

"យើងដឹងថាមនុស្សជាច្រើននៅក្រុងកំពុងជួបបញ្ហាលុយកាកក្នុងគ្រាដ៏លំបាកនេះ។ យើងក៏ចង់ជួយពួកគេឲ្យបានកាន់តែច្រើនតាមដែលអាចធ្វើបាន។ តែក៏ត្រូវប្រាកដថា យើងនៅតែអាចប្រមូលពន្ធបានគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ដល់សេវាកម្ម ក៏ដូចជាគុណភាពនៃប្រកបការងាររបស់សាលាក្រុង"។ លោក Arrigo បន្ត "ក្រុមរបស់យើងនឹងបន្តស្វែងរកវិធីផ្សេងៗ ដើម្បីជួយសម្រួលដល់បន្ទុកផ្នែកហិរញ្ញវត្ថុដល់ប្រជាជន ក៏ដូចជាម្ចាស់អាជីវកម្មទាំងអស់ដែលរស់នៅក្រុងនេះ"។

សាលាក្រុង នឹងនៅតែបន្តផ្តល់ព័ត៌មានអំពីស្ថានការណ៍នៃជំងឺ COVID-19 តាមរយៈ Revere.org/coronavirus ដើម្បីឲ្យមហាជនដឹងឮពីករណីថ្មីៗដែលកើតឡើងនៅក្នុងក្រុង Revere រួមទាំងការប្រៀបធៀបទៅនឹងក្រុងនានា ក៏ដូចជាសាធារណរដ្ឋទាំងមូល៕

###